វិញ្ញាសា និងអត្រាកំណែ
ជ្រើសរើសគ្រូកិច្ចព្រមព្រៀងមធ្យមសិក្សាភូមិតវិទ្យាល័យ

ឯកទេស ៖ ប្រវត្តិវិទ្យា

រយៈពេល ៖ ២ម៉ោង

សម័យប្រឡង ៖ ១៩ តុលា ២០២៦



រៀបរៀងដោយ៖ **គរុនិស្សិត ង៉ា វុត្ថា ឯកទេសប្រវត្តិវិទ្យា**

សំណួរ

១. មូលហេតុអ្វីខ្លះដែលយុវជនត្រូវសិក្សាពីប្រវត្តិសាស្ត្រកម្ពុជា និងប្រវត្តិសាស្ត្រពិភពលោក ?(**២០ពិន្ទុ**)

២.ចូររាប់ឈ្មោះមេដឹកនាំកំពូលៗក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)។តើមានមូលហេតុអ្វីខ្លះបានជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើកយកមេដឹកនាំទាំងនេះមកកាត់ទោស?(**៣០ពិន្ទុ**)

៣.ប្រទេសកម្ពុជាសម្បូរទៅដោយស្ថានីយបុរេប្រវត្តិសាស្ត្រ។ ចូររៀបរាប់ឈ្មោះស្ថានីយឱ្យបានចំនួន៥និងបញ្ជាក់ពីទីតាំងភូមិសាស្ត្រនៃស្ថានីយទាំងនោះ។(**១៥ពិន្ទុ**)

៤.មុននឹងប្រកាសឯករាជ្យជាតិនិងធ្វើពិធីលទ្ធិទេវរាជ នៅលើភ្នំគូលែន តើព្រះបាទជ័យវរ្ម័នទី២ទ្រង់បានលើករាជធានីទៅកន្លែងណាខ្លះ? មានឈ្មោះអ្វីខ្លះនិងស្ថិតនៅទីណា? មូលហេតុអ្វីបានជាព្រះអង្គផ្លាស់ប្តូររាជធានីជាបន្តបន្ទាប់បែបនេះ? (**១៥ពិន្ទុ**)

៥.ក្រោយសង្គ្រាមលោកលើកទី២ប្រទេសនៅឥណ្ឌូចិនបានទទួលឯករាជ្យជាបន្តបន្ទាប់។តើប្រទេសវៀតណាមនិងឡាវទទួលបានឯករាជ្យតាមរបៀបណា? ក្រោយទទួលបានឯករាជ្យតើបណ្តាប្រទេសនៅឥណ្ឌូចិនទទួលបានសន្តិភាពពិតប្រាកដដែរឬទេ? ចូរពន្យល់។(**២០ពិន្ទុ**)

អត្រាកំណែល និងចម្លើយ

(អត្រាកំណែក្រៅផ្លូវការ - រៀបរៀងដោយគុនិស្សិត វ៉ា វុត្ថា ឯកទេសប្រវត្តិវិទ្យា)

១. មូលហេតុដែលយុវជនត្រូវសិក្សាពីប្រវត្តិសាស្ត្រកម្ពុជា និងប្រវត្តិសាស្ត្រពិភពលោក

+ និយមន័យ

- ប្រវត្តិសាស្ត្រគឺជាវិទ្យាសាស្ត្រសង្គមមួយដែលសិក្សាស្រាវជ្រាវអំពីសកម្មភាពប្រពៃណីវប្បធម៌អរិយធម៌របៀបរស់នៅការគ្រប់គ្រងរដ្ឋនិងការវិវត្តនៃសង្គមមនុស្សជាតិជាតិក៏ដូចជាពិភពលោកទាំងមូលដែលបានកើតឡើងរួចមកហើយនៅក្នុងអតីតកាល ដោយផ្អែកលើកស្តុតាង និងឯកសារយោងច្បាស់លាស់ ។

+ ប្រវត្តិសាស្ត្រកម្ពុជា

- ជួយឱ្យយុវជនស្គាល់ពីឫសគល់ជាតិ វប្បធម៌ និងប្រភពកំណើតពូជសាសន៍ខ្លួន។
- ធ្វើឱ្យស្គាល់ពីភាពអស្ចារ្យនៃអរិយធម៌ អំណាច និងទឹកដីដ៏រុងរឿងនាសម័យអង្គរ។
- បង្កើតមនសិការស្នេហាជាតិ និងការពារអធិបតេយ្យភាពជាតិឱ្យបានគង់វង្ស។
- ធ្វើឱ្យយុវជនមានសេចក្តីថ្លៃថ្នូរ មានមោទនភាពជាតិ និងមិនរលាយចូលវប្បធម៌បរទេស។
- រំលឹកគុណដល់ការលះបង់ និងវីរភាពដ៏ឧត្តុង្គឧត្តមរបស់បុព្វបុរសជំនាន់មុន។
- ដកស្រង់មេរៀនពីការបែកបាក់ផ្ទៃក្នុង និងរបបប្រល័យពូជសាសន៍កុំឱ្យកើតមានជាថ្មី។
- ជំរុញឱ្យយុវជនយល់ច្បាស់ពីតម្លៃនៃការរួមគ្នាថែរក្សា និងការពារសន្តិភាពបច្ចុប្បន្ន។
- ផ្តល់ចំណេះដឹងផ្នែកប្រវត្តិសាស្ត្រទឹកដី ដើម្បីចូលរួមការពារបូរណភាពទឹកដីជាតិ។
- ពង្រឹងសមត្ថភាពការគិត បែបវិភាគព្រឹត្តិការណ៍ ដោយហេតុផលនិងកស្តុតាងច្បាស់លាស់។
- យកបទពិសោធន៍ទាំងចំណុចខ្លាំងនិងខ្សោយពីអតីតកាល មកធ្វើជាមូលដ្ឋានអភិវឌ្ឍប្រទេស។

+ ប្រវត្តិសាស្ត្រពិភពលោក

- ជួយឱ្យយុវជនពង្រីកទស្សនវិស័យ ស្វែងយល់ពីការវិវត្តនៃសង្គមមនុស្ស និងអរិយធម៌សកលលោក។
- ធ្វើឱ្យយល់ដឹងពីប្រព័ន្ធគ្រប់គ្រងនយោបាយ របបដឹកនាំ និងការផ្លាស់ប្តូរសេដ្ឋកិច្ចរបស់ប្រទេសនានា។
- ផ្តល់ចំណេះដឹងពីឥទ្ធិពលនៃភូមិសាស្ត្រនយោបាយ និងទំនាក់ទំនងអន្តរជាតិក្នុងយុគសម័យផ្សេងៗ។
- ជួយឱ្យយុវជនយល់ពីឫសគល់ និងផលវិបាកនៃសង្គ្រាមធំៗ ដូចជាសង្គ្រាមលោក និងសង្គ្រាមត្រជាក់។
- បណ្តុះស្មារតីអត់ឱន គោរពភាពចម្រុះនៃវប្បធម៌ ពូជសាសន៍ និងសាសនានៅលើពិភពលោក។
- ធ្វើឱ្យយល់ដឹងពីការកកើត និងតួនាទីរបស់អង្គការអន្តរជាតិ ដូចជាអង្គការសហប្រជាជាតិជាដើម។
- ជួយឱ្យយុវជនងាយស្រួលធ្វើសមាហរណកម្មខ្លួន និងបន្សាំខ្លួនទៅនឹងយុគសម័យសកលភាវូបនីយកម្ម។
- ផ្តល់បទពិសោធន៍ពីការរីកចម្រើនខាងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបដិវត្តឧស្សាហកម្មរបស់ពិភពលោក។
- ជួយឱ្យយុវជនចេះប្រៀបធៀប និងវិភាគព្រឹត្តិការណ៍អន្តរជាតិ ដោយផ្អែកលើហេតុផលសកល។
- បណ្តុះគំនិតជាពលរដ្ឋសកល ដែលចូលរួមចំណែកក្នុងការកសាង និងថែរក្សាសន្តិភាពពិភពលោក។

(មានចម្លើយត្រឹមត្រូវផ្សេងទៀត)

២.មេដឹកនាំកំពូលៗក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានដូចជា

- ប៉ុល ពត (សាឡុត ស) ជាលេខាបក្សកុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រី។
- នួន ជា (បងធំទី២) ជាអនុលេខាបក្ស និងជាប្រធានសភាតំណាងប្រជាជនបដិវត្តន៍។
- ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ (ប្រមុខរដ្ឋ)។
- អៀង សារី ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស។
- សុន សេន ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ។
- ឈិត ជឿន (តាម៉ុក) ជាលេខាភូមិភាគនិរតី និងជាអគ្គមេបញ្ជាការកងទ័ពជាតិ។
- កាំង ហ្គេកអ៊ាវ (ហៅ ឌុច) ជាប្រធានមន្ទីរសន្តិសុខ ស-២១ (គុកទួលស្លែង)។[1]

(បញ្ជាក់បេក្ខជនអាចរៀបរាប់តែឈ្មោះមេដឹកនាំកំពូលៗក៏បានពិន្ទុដូចគ្នា)

មូលហេតុបានជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(សាលាក្តីខ្មែរក្រហម)លើកយកមេដឹកនាំទាំងនេះមកកាត់ទោសព្រោះមូលហេតុដូចជា ៖

+ ការកេងកម្លាំងពលកម្ម

- ការបង្ខំឱ្យធ្វើការងារប្តូរវេនទាំងយប់ទាំងថ្ងៃ គ្មានពេលសម្រាកសម្រាប់ស្តារកម្លាំងកាយសម្បទាឡើងវិញ។
- ការចាត់តាំងឱ្យធ្វើការងារដោយបង្ខំក្នុងតំបន់គ្រោះថ្នាក់ ដូចជាការបោសសម្អាតមីន និងការកាប់ឆ្ការព្រៃក្រាស់ៗ។
- ការអនុវត្តប្រព័ន្ធកូតាការងារដ៏តឹងរ៉ឹង បើធ្វើមិនទាន់ផែនការនឹងត្រូវកាត់បន្ថយរបបអាហារ ឬរងទណ្ឌកម្មវាយដំ។
- ការបង្ខំឱ្យកុមារនិងមនុស្សចាស់ធ្វើពលកម្មធ្ងន់ធ្ងរហួសពីកម្រិតកាយសម្បទាដែលជាការរំលោភសិទ្ធិកុមារ។
- ការដកហូតទ្រព្យសម្បត្តិនិងផលដំណាំដែលប្រជាជនផលិតបានទាំងអស់យកទៅដាក់ជាកម្មសិទ្ធិរួមរបស់អង្គការ។

+ ការសម្លាប់មនុស្ស

- ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើជាតិសាសន៍ខ្លួនឯង។
- ការអនុវត្តគោលនយោបាយ«បោសសម្អាតផ្ទៃក្នុង»សម្លាប់សមាជិកកម្មាភិបាលខ្លួនឯងដែលសង្ស័យថាក្បត់ ។
- ការសម្លាប់មនុស្សដោយគ្មានការកាត់ទោសតាមផ្លូវច្បាប់ ឬគ្មានការស៊ើបអង្កេតត្រឹមត្រូវ គឺផ្អែកលើតែការសង្ស័យ។
- បង្កើតប្រព័ន្ធគុកសម្ងាត់នៅទូទាំងប្រទេសដើម្បីធ្វើទារុណកម្មបង្ខំឱ្យឆ្លើយសារភាពមុននឹងយកទៅកម្ទេចចោល។
- ការលាក់បាំងកសុតាងនៃការសម្លាប់ដោយយកសាកសពទៅទម្លាក់ចោលក្នុងរណ្តៅដីរួមឬហៅថា«វាលពិឃាត»។
- សម្លាប់មនុស្សស្លូតបូត មិនមានកម្លាំងតតាំង ដោយគ្មានហេតុផលច្បាស់លាស់ ។
- សម្លាប់អ្នកចេះដឹងដោយចោទថាជាខ្មាំងក្បត់អង្គការ ។

+ សង្គ្រាមជាមួយប្រទេសជិតខាង

- ការធ្វើសង្គ្រាមតាមព្រំដែនជាមួយប្រទេសវៀតណាម ។
- ធ្វើទុក្ខបុកម្នេញការបណ្តេញចេញនិងសម្លាប់ជនអន្តោប្រវេសន៍ឬជនជាតិភាគតិចដែលមានសញ្ជាតិផ្សេងៗ ។
- ការរំលោភលើច្បាប់មនុស្សធម៌អន្តរជាតិតាមរយៈការបើកការវាយប្រហារលើជនស៊ីវិលរស់នៅតាមតំបន់ព្រំដែន។
- ការបដិសេធរាល់យន្តការចរចាដោយសន្តិវិធី និងការកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយបណ្តាប្រទេសក្នុងតំបន់។

[1] ប្រវត្តិវិទ្យាថ្នាក់ទី១២(ថ្មី) ក្រសួងអប់រំ យុវជន និងកីឡា ទំព័រ២៥

+ លុបបំបាត់ វប្បធម៌ សាសនា សេរីភាព

- បំផ្លិចបំផ្លាញវត្តអារាម ធ្សឹកព្រះសង្ឃ និងបំបាត់មិនឱ្យមានកម្មវិធីបុណ្យនានា ។
- លុបបំបាត់រូបិយប័ណ្ណសេដ្ឋកិច្ចទីផ្សារនិងការបង្កើតរបបសហករណ៍ដែលគ្មានសេរីភាពក្នុងការដោះដូរទំនិញ។
- ការដុតបំផ្លាញបំបែកបំបាក់សៀវភៅឯកសារប្រវត្តិសាស្ត្របណ្ណាល័យស្នាដៃសិល្បៈវប្បធម៌សំខាន់ៗរបស់ជាតិ។
- ការហាមឃាត់ការប្រើប្រាស់ពាក្យពេចន៍ទំនាក់ទំនងបែបប្រពៃណីដោយជំនួសមកវិញនូវភាសាបដិវត្តន៍ដាច់ខាត។
- ការរឹតត្បិតសេរីភាពនៃការបង្កើតគ្រួសារដោយតម្រូវឱ្យមានការអនុញ្ញាតនិងចាត់តាំងរៀបការ ពីសំណាក់អង្គការ។
- ការបំផ្លិចបំផ្លាញប្រព័ន្ធអប់រំទាំងស្រុងតាមរយៈការបិទសាលារៀនវិទ្យាល័យនិងសាកលវិទ្យាល័យទូទាំងប្រទេស។

+ ផ្តល់យុត្តិធម៌ចំពោះជនរងគ្រោះ

- ការទទួលស្គាល់ការឈឺចាប់ផ្លូវចិត្តនិងសងដំនឿចិត្តមកវិញដល់ជនរងគ្រោះ ។
- ការបើកសវនាការជាសាធារណៈ ដើម្បីអនុញ្ញាតឱ្យប្រជាជនទូទាំងប្រទេសបានដឹងពីដំណើរការច្បាប់ពិតប្រាកដ។
- កសាងបណ្ណសារដ្ឋានគុណាការដើម្បីរក្សាទុកជាភស្តុតាងប្រវត្តិសាស្ត្រផ្លូវការការពារកុំឱ្យមានការប្រកែកបដិសេធ។
- ជួយឱ្យជនរងគ្រោះមានឱកាសប្រឈមមុខផ្ទាល់ជាមួយអតីតមេដឹកនាំដែលធ្លាប់ធ្វើបាបខ្លួននៅក្នុងសាលសវនាការ។
- ស្តារកិត្តិយសនិងសេចក្តីថ្លៃថ្នូរជូនអ្នកដែលបានស្លាប់បាត់បង់ជីវិតកំណត់ឱ្យច្បាស់ថាពួកគេជាជនរងគ្រោះនៃឧក្រិដ្ឋកម្ម។

+ ជាមេរៀនសម្រាប់មេដឹកនាំជំនាន់ក្រោយ

- ការពង្រឹងគោលការណ៍នីតិរដ្ឋនិងយុត្តិធម៌អន្តរជាតិ។
- បង្ហាញឱ្យឃើញថាគ្មានបុគ្គលណាម្នាក់អាចស្ថិតនៅពីលើច្បាប់បានឡើយ។
- អប់រំមេដឹកនាំឱ្យយល់ពីផលវិបាកនៃការអនុវត្តមនោគមវិជ្ជាជ្រុលនិយម និងការផ្តាច់ការអំណាច។
- បណ្តុះស្មារតីទទួលខុសត្រូវខ្ពស់ចំពោះរាល់សេចក្តីសម្រេចចិត្តនយោបាយដែលអាចជះឥទ្ធិពលដល់វាសនាជាតិ។
- ថែរក្សាសន្តិភាពស្ថិរភាពសង្គមនិងការការពារសិទ្ធិមនុស្សជាសកលដើម្បីទប់ស្កាត់ការកើតឡើងវិញនៃអំពើឃោរឃៅ។

(មានចម្លើយត្រឹមត្រូវផ្សេងទៀត)

៣. ឈ្មោះស្ថានីយនៃក្នុងប្រទេសកម្ពុជាមានដូចជា ៖

- ស្ថានីយល្អាងស្ពាន ស្ថិតនៅក្នុងខេត្តបាត់ដំបង។
- ស្ថានីយក្រាលរមាស ស្ថិតនៅក្នុងខេត្តកំពត។
- ស្ថានីយសំរោងសែន ស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង។
- ស្ថានីយតំបន់អង្គរ ស្ថិតនៅក្នុងខេត្តសៀមរាប។
- ស្ថានីយអង្គរបុរី ស្ថិតនៅក្នុងខេត្តតាកែវ។
- ស្ថានីយអន្លង់ផ្តៅ ស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង។
- ស្ថានីយកូមិស្នាយ ស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យ។
- ស្ថានីយកូមិមូល ស្ថិតនៅក្នុងខេត្តកំពង់ចាម (បច្ចុប្បន្ននៅក្នុងខេត្តត្បូងឃ្មុំ)។
- ស្ថានីយម្លូព្រៃ ស្ថិតនៅក្នុងខេត្តស្ទឹងត្រែង ។[2]

(បេក្ខជនដាក់ត្រឹម៥ក៏ទទួលបានពិន្ទុដូចគ្នា)

[2] សិក្សាសង្គមថ្នាក់ទី១០(ថ្មី) ក្រសួងអប់រំ យុវជន និងកីឡា ទំព័រ១០៦

៤.មុននឹងប្រកាសឯករាជ្យជាតិនិងធ្វើពិធីលទ្ធិទេវរាជនៅលើភ្នំគូលែនព្រះបាទជ័យវរ្ម៉ែនទី២ ទ្រង់បានលើករាជធានីទៅកាន់

- រាជធានីឥន្ទ្របុរៈ ៖ ជាព្រះរាជធានីដំបូង ដែលគេសន្មិដ្ឋានថាស្ថិតនៅខេត្តកំពង់ចាមសព្វថ្ងៃ។
- រាជធានីហរិហរាល័យ ៖ ដែលសព្វថ្ងៃត្រូវនឹងតំបន់ប្រាសាទព្រៃមន្ទីរ បាគង ព្រះគោ និងលលៃ ខេត្តសៀមរាប ។
- រាជធានីអមរេន្ទ្របុរៈ៖ដែលសព្វថ្ងៃស្ថិតនៅក្នុងខេត្តសៀមរាប ។
- រាជធានីមហេន្ទ្របព៌ត ៖ ត្រូវនិងភ្នំគូលែនជាកន្លែងដែលព្រះអង្គប្រារព្ធពិធីទេវរាជ ។[3]

មូលហេតុដែលព្រះអង្គផ្លាស់ប្តូររាជធានីជាបន្តបន្ទាប់បែបនេះព្រោះ៖

- ដើម្បីគេចចេញពីការគាបសង្កត់ ការធ្វើទុក្ខបុកម្នេញ និងការតាមយាយីផ្នែកយោធាពីសំណាក់ពួកជ្វា ។
- ដើម្បីស្វែងរកទីតាំងភូមិសាស្ត្រយុទ្ធសាស្ត្រដែលមានសុវត្ថិភាពខ្ពស់និងងាយស្រួលក្នុងការការពារខ្លួន។
- ដើម្បីបង្រួបបង្រួមអាណាចក្រចេនឡាទឹកលិចនិងចេនឡាដីគោកដែលមិនចុះសម្រុងទៅជាធ្លុងមួយឡើងវិញ។
- ដើម្បីស្វែងរកតំបន់កណ្តាលនៃអាណាចក្រដែលមានអំណោយផលដល់ការប្រមូលកម្លាំងទ័ពកម្លាំងប្រជាជន។
- ដើម្បីស្វែងរកតំបន់វាលទំនាបដែលមានប្រភពទឹកគ្រប់គ្រាន់ងាយស្រួលធ្វើកសិកម្មសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ។
- បង្ក្រាបចំពោះតំបន់ណាដែលមិនព្រមទទួលយកអំណាចឥទ្ធិពលរបស់ទ្រង់ ។
- ចងសម្ព័ន្ធភាពជាមួយតំបន់នីមួយៗដើម្បីពង្រឹងអំណាចនិងការគាំទ្រពីស្តេចក្រាញ់ ។
- ចាត់តាំងអ្នកដែលទុកចិត្តដោយលើកគោរម្យងារស្តេចក្រាញ់តាមតំបន់ ។
- ស្វែងរកអ្នកមានសមត្ថភាពចូលរួមបម្រើប្រទេសជាតិ ។

(មានចម្លើយត្រឹមត្រូវផ្សេងទៀត)

៥.ក្រោយសង្ក្រាមលោកលើកទី២ប្រទេសនៅឥណ្ឌូចិនបានទទួលឯករាជ្យជាបន្តបន្ទាប់ ប្រទេសវៀតណាមនិងឡាវទទួលបានឯករាជ្យតាមរយៈសន្ធិសីទទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ ។

ក្រោយទទួលបានឯករាជ្យបណ្តាប្រទេសនៅឥណ្ឌូចិនទទួលឥទ្ធិពលដូចជា ៖

+ប្រទេសវៀតណាម

- វៀតណាមចែកជា២ មានវៀតណាមខាងជើង និងវៀតណាមខាងត្បូង។
- វៀតណាមខាងជើងគាំទ្រដោយប្លុកកុម្មុយនីស្ត វៀតណាមខាងត្បូងគាំទ្រដោយប្លុកសេរី ។
- ការបង្កើតរណសិរ្សវៀតមិញដោយលោកហូជីមិញដឹកនាំការតស៊ូប្រដាប់អាវុធប្រឆាំងកងទ័ពអាណានិគមបារាំង។
- ការផ្ទុះឡើងនៃសង្ក្រាមឥណ្ឌូចិនលើកទី១។
- ការប្រើប្រាស់យុទ្ធសាស្ត្រសង្ក្រាមប្រជាជននិងសង្ក្រាមទ័ពព្រៃ។
- ការអូសបន្លាយនៃសង្ក្រាមបង្រួបបង្រួមជាតិដ៏រុំរៃ៉។
- ប្រជាជនរស់នៅដោយភិតភ័យ ដោយសារសង្ក្រាមស៊ីវិល ។
- អធិបតេយ្យភាព ចលាចលក្នុងប្រទេស ។

---

[3] ប្រវត្តិសាស្ត្រកម្ពុជា (បណ្ឌិត វង់ សុធារ៉ា) ទំព័រពាឥ

+ប្រទេសឡាវ

- ការបង្កើតចលនាឡាវឥស្សរៈនិងកងទ័ពប៉ៈថេតឡាវដើម្បីបើកការតស៊ូប្រដាប់អាវុធប្រឆាំង។
- ការធ្លាក់ចូលទៅក្នុងវិបត្តិសង្គ្រាមស៊ីវិលផ្ទៃក្នុងរវាងប្តុកកុម្មុយនីស្តនិងប្តុករាជានិយមគាំទ្រសេរី។
- ទទួលឥទ្ធិពលពីសង្គ្រាមនៅវៀតណាម ។
- ការអូសបន្លាយនៃសង្គ្រាមបង្រួបបង្រួមជាតិដ៏ពុំរ៉ៃ។
- ប្រជាជនរស់នៅដោយភិតភ័យ ដោយសារសង្គ្រាមស៊ីវិល ។
- អធិបតេយ្យភាព ចលាចលក្នុងប្រទេស ។
- ការរងគ្រោះដោយសារការជ្រៀតជ្រែកពីបរទេស។

+ប្រទេសកម្ពុជា

- ការទទួលបានឯករាជ្យពេញលេញ ។
- រំសាយកងទ័ពខ្មែរឥស្សរៈទាំងស្រុង ។
- កងទ័ពបរទេសវៀតមិញដកចេញពីទឹកដីខ្មែរទាំងស្រុង។
- រៀបចំឱ្យមានការបោះឆ្នោតដោយសេរីក្នុងការជ្រើសរើសមេដឹកនាំប្រទេស ។
- ការការពារយ៉ាងដាច់ខាតនូវអព្យាក្រឹតភាព និងអធិបតេយ្យភាព ។
- មានការរីកចម្រើន អភិវឌ្ឍគ្រប់វិស័យ ។
- មានសន្តិភាព ស្ថិរភាពរយៈពេល១៥ឆ្នាំ ។

(មានចម្លើយត្រឹមត្រូវផ្សេងទៀត)